KHMER

# ធម្មនុញ្ញអូស្ត្រាលីស្តីអំពីសិទ្ធិមើលថែសុខភាព ក្នុងរដ្ឋវិចតូរីយ៉ា



AUSTRALIAN COMMISSION ON SAFETY AND QUALITY IN HEALTHCARE

A Victorian Government initiative

Victoria The Place To Be

# ធម្មនុញ្ញអូស្ត្រាលីស្តីអំពីសិទ្ធិមើលថែសុខភាព

*ធម្មនុញ្ញអូស្ត្រាលីស្តីអំពីសិទ្ធិមើលថែសុខភាព* ពិពណ៌នាអំពីសិទ្ធិរបស់អ្នកជម្ងឺ អ្នកប្រើប្រាស់ និងអ្នកដទៃទៀតដែលប្រើប្រាស់ប្រព័ន្ធមើលថែសុខភាពអូស្ត្រាលី។ សិទ្ធិទាំងនេះមានសារៈសំខាន់ដើម្បីធ្វើឲ្យប្រាកដថាទោះបីជានៅទីណា និងពេលណាដែលប្រព័ន្ធមើលថែសុខភាពបានផ្តល់ឲ្យ ប្រព័ន្ធនេះត្រូវមានគុណភាពខ្ពស់ ហើយមានសុវត្ថិភាព។

ធម្មនុញ្ញទទួលស្គាល់ថាអ្នកដែលទទួលការមើលថែសុខភាព និងអ្នកដែលផ្តល់ការមើលថែសុខភាព ទាំងអស់គ្នាមានចំណែកសំខាន់នៅក្នុងតួនាទីដើម្បីឲ្យបានសំរេចនូវសិទ្ធិមើលថែសុខភាព។ ធម្មនុញ្ញនេះអនុញ្ញាតឲ្យអ្នកជម្ងឺ អ្នកប្រើប្រាស់ គ្រួសារ អ្នកមើលថែ និងកិច្ចបំរើផ្តល់ការមើលថែ ដើម្បីចែករំលែកការយល់ដឹងអំពីសិទ្ធិរបស់អ្នកទទួលការមើលថែសុខភាព។ ការចែករំលែកការយល់ដឹងនេះ ជួយឲ្យមនុស្សគ្រប់រូបធ្វើការជាមួយគ្នាឆ្ពោះទៅរកប្រព័ន្ធមើលថែសុខភាពមួយដែលមានសុវត្ថិភាព និងគុណភាពខ្ពស់។ ភាពជាដៃគូដ៏ពិតប្រាកដរវាងអ្នកជម្ងឺ អ្នកប្រើប្រាស់ និងស្ថាប័នផ្តល់ការមើលថែគឺមានសារសំខាន់ ដើម្បីឲ្យមនុស្សគ្រប់រូបបានសំរេចនូវលទ្ធផលប្រសើរបំផុត ដែលអាចធ្វើទៅបាន។

## គោលការណ៍ណែនាំ

គោលការណ៍ទាំងនេះពិពណ៌នា ថាតើធម្មនុញ្ញនេះអនុវត្តនៅក្នុងប្រព័ន្ធមើលថែសុខភាពអូស្ត្រាលីបែបយ៉ាងដូចម្តេច។

១. មនុស្សគ្រប់រូបមានសិទ្ធិទទួលយកការមើលថែសុខភាព ហើយសិទ្ធិនេះមានសារៈសំខាន់សំរាប់ឲ្យធម្មនុញ្ញមានន័យខ្លឹមសារ។

២. រដ្ឋាភិបាលអូស្ត្រាលីបានប្តេជ្ញាអនុវត្តតាមកិច្ចព្រមព្រៀងអន្តរជាតិស្តីអំពីសិទ្ធិមនុស្សដែលទទួលស្គាល់សិទ្ធិរបស់មនុស្សគ្រប់រូប ដើម្បីទទួលបាននូវសុខភាពខាងផ្លូវកាយ និងផ្លូវចិត្តដែលមានបទដ្ឋានខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន។

៣. ប្រទេសអូស្ត្រាលី គឺជាសង្គមមួយដែលកើតឡើងពីមនុស្សដែលមានវប្បធម៌ និងរបៀបរស់នៅផ្សេងៗគ្នា ហើយធម្មនុញ្ញទទួលស្គាល់ និងគោរពចំពោះភាពខុសៗគ្នាទាំងនេះ។

## សិទ្ធិរបស់ប្អូនៗនៅក្នុងធម្មនុញ្ញអូស្ត្រាលីស្ដីអំពីសិទ្ធិមើលថែសុខភាព

- **លទ្ធភាពទទួល** – សិទ្ធិទទួលយកការមើលថែសុខភាព។
- **សុវត្ថិភាព** – សិទ្ធិទទួលយកការមើលថែសុខភាពដែលមានសុវត្ថិភាព និងគុណភាពខ្ពស់។
- **ការគោរព** – សិទ្ធិឲ្យអ្នកដទៃគោរព ហើយឲ្យអ្នកដទៃប្រព្រឹត្តចំពោះខ្លួនប្រកបដោយភាពថ្លៃថ្នូ និងសេចក្ដីរាប់អាន
- **ការទាក់ទង** – សិទ្ធិទទួលយកព័ត៌មានអំពីកិច្ចបំរើ ការព្យាបាល ជំរើស និងតម្លៃដោយរបៀបច្បាស់លាស់ ហើយបើកចំហ។
- **ការចូលរួម** – សិទ្ធិឲ្យគេរាប់បញ្ចូលនៅក្នុងការធ្វើសេចក្ដីសំរេច ហើយធ្វើជំរើសអំពីការមើលថែសុខភាពរបស់ប្អូនៗ។
- **ភាពជាឯកជន** – សិទ្ធិរក្សាទុកភាពជាឯកជន និងការសម្ងាត់នៃព័ត៌មានផ្ទាល់ខ្លួនរបស់ប្អូនៗ។
- **យោបល់** – សិទ្ធិបញ្ចេញយោបល់អំពីការមើលថែសុខភាពរបស់ប្អូនៗ និងដើម្បីលើកយកការព្រួយបារម្ភរបស់ប្អូនៗមកឲ្យគេដោះស្រាយ។

# តើធម្មនុញ្ញមាននេះន័យយ៉ាងដូចម្តេចនៅក្នុងរដ្ឋវិចតូរីយ៉ា?

កូនសៀវភៅនេះពិពណ៌នាអំពី*ធម្មនុញ្ញអូស្ត្រាលីស្តីអំពីសិទ្ធិមើលថែសុខភាព* ហើយថាតើវាមានន័យយ៉ាងណាដែរសំរាប់ប្អូនៗដែលជាអ្នកជម្ងឺ អ្នកប្រើប្រាស់ សមាជិកគ្រួសារ ឬអ្នកមើលថែដែលប្រើប្រាស់ប្រព័ន្ធមើលថែសុខភាពអូស្ត្រាលី។ ធម្មនុញ្ញនេះដាក់ជំនួសធម្មនុញ្ញនៃអ្នកជម្ងឺនៅតាមមន្ទីរពេទ្យសាធារណៈ។

សិទ្ធិទាំងនេះអនុវត្តចំពោះកិច្ចបំរើមើលថែសុខភាពទាំងអស់នៅក្នុងរដ្ឋវិចតូរីយ៉ា។ នេះរាប់បញ្ចូលទាំងអ្នកដែលប្រើប្រាស់មន្ទីរពេទ្យសាធារណៈ និងមន្ទីរពេទ្យឯកជន គ្លីនិកពិនិត្យជំងឺទូទៅ គ្រូពេទ្យឯកទេស កិច្ចបំរើមើលថែមនុស្សចាស់ និងមនុស្សមានភាពពិការ កិច្ចបំរើផ្នែកសុខភាពផ្លូវចិត្ត មជ្ឈមណ្ឌលសុខភាពសហគមន៍ ហើយនិងសម្ព័ន្ធស្ថាប័នមើលថែសុខភាពដូចជាអ្នកចិត្តសាស្រ្ត គ្រូពេទ្យធ្មេញ គ្រូពេទ្យអ្នកព្យាបាលរោគតាមវិធីប្តូរអាហារហាត់ប្រាណ និងកំដៅ និងគ្រូពេទ្យជំនាញព្យាបាលជំងឺផ្លូវចិត្ត និងកាយដោយឲ្យអ្នកជំងឺចូលរួមធ្វើសកម្មភាពផ្សេងៗ។

## អំពីកូនសៀវភៅនេះ

កូនសៀវភៅនេះប្រាប់ប្អូនៗអំពីអ្វីដែលប្អូនៗអាចរំពឹងទុក ពីកិច្ចបំរើមើលថែសុខភាពនៅក្នុងរដ្ឋវិចតូរីយ៉ា និងកន្លែងដែលត្រូវទៅដើម្បីសុំជំនួយ ប្រសិនបើប្អូនៗមានកង្វល់អំពីកិច្ចបំរើដែលប្អូនៗស្វែងរក ឬកំពុងទទួល។

## សិទ្ធិមើលថែសុខភាព និងសិទ្ធិមនុស្ស

រដ្ឋាភិបាលអូស្ត្រាលី និងរដ្ឋាភិបាលរដ្ឋវិចតូរីយ៉ាបានប្តេជ្ញាអនុវត្តតាមកិច្ចព្រមព្រៀងអន្តរជាតិផ្នែកសិទ្ធិមនុស្សមួយចំនួន ដែលទទួលស្គាល់សិទ្ធិរបស់មនុស្សគ្រប់រូបក្នុងការទទួលបាននូវសុខភាពខាងផ្លូវកាយ និងផ្លូវចិត្តដែលមានបទដ្ឋានខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន។ គេទទួលស្គាល់សិទ្ធិរបស់ប្អូនៗដើម្បីទទួលយកការមើលថែសុខភាព និងកិច្ចបំរើដទៃទៀតដែលសំខាន់សំរាប់សុខភាពរាប់បញ្ចូលទាំងទឹកប្រើប្រាស់ដែលមានសុវត្ថិភាព លំនៅដ្ឋានហើយនិងការអប់រំទាក់ទិននឹងសុខភាព។

នៅក្នុងរដ្ឋវិចតូរីយ៉ា កិច្ចបំរើមើលថែសុខភាពដែលរដ្ឋផ្គត់ផ្គង់ថវិកា ត្រូវគោរពទៅតាមធម្មនុញ្ញវិចតូរីយ៉ានៃសិទ្ធិមនុស្ស និងច្បាប់ការទទួលខុសត្រូវ ឆ្នាំ២០០៦ ដែលការពារសិទ្ធិមនុស្សជាច្រើន។ មើលវ៉ិបសាយ www.patientcharter.health.vic.gov.au ដើម្បីឲ្យដឹងថា តើការនេះអាចប៉ះពាល់ដល់សិទ្ធិមើលថែសុខភាពរបស់ប្អូនៗយ៉ាងណាដែរ។

## អ្នកប្រើប្រាស់ អ្នកជម្ងឺ និងស្ថាប័នផ្តល់កិច្ចបំរើមើលថែសុខភាព

**អ្នកប្រើប្រាស់** គឺមនុស្សដែលប្រើប្រាស់កិច្ចបំរើសុខភាពក្នុងពេលបច្ចុប្បន្ន ឬអ្នកប្រើប្រាស់ទៅអនាគត រាប់បញ្ចូលទាំងអ្នកជម្ងឺនៅមន្ទីរពេទ្យ។ នេះមានរួមទាំងកូនក្មេង ស្ត្រី និងបុរស មនុស្សរស់នៅដោយមានពិការភាព មនុស្សមកអំពីប្រភពវប្បធម៌ និងជំនឿផ្សេងៗគ្នា ស្ថានភាពរស់នៅក្នុងវិស័យសេដ្ឋកិច្ចសង្គម និងស្ថានភាពសង្គម ចំណូលចិត្តខាងផ្នែកផ្លូវភេទ និងស្ថានភាពសុខភាពផ្សេងៗគ្នា។

**ស្ថាប័នផ្តល់កិច្ចបំរើមើលថែសុខភាព** គឺជាគ្រូពេទ្យអាជីពដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ដើម្បីផ្តល់នូវការមើលថែសុខភាពប្អូនៗ។

**កិច្ចបំរើមើលថែសុខភាព** គឺជាអង្គការទទួលខុសត្រូវចំពោះការផ្តល់នូវកិច្ចបំរើមើលថែសុខភាព។

## លទ្ធភាពទទួល

**ប្អូនៗមានសិទ្ធិទទួលយកការមើលថែសុខភាពដែលប្អូនៗត្រូវការ។ សិទ្ធិនេះបានទទួលការផ្គត់ផ្គង់ពីមេឌីឃែរ (Medicare) ដែលផ្តល់នូវលទ្ធភាពទទួលយកការព្យាបាលពីវេជ្ជបណ្ឌិតដោយឥតគិតថ្លៃ ឬដែលរដ្ឋជួយចេញថ្លៃ និងលទ្ធភាពទទួលយកកិច្ចបំរើនៅតាមមន្ទីរពេទ្យសាធារណៈដោយឥតគិតថ្លៃ។**

ប្អូនៗមានសិទ្ធិទទួលយកការមើលថែសុខភាពដែលមានគុណភាពខ្ពស់ ដែលបំពេញទៅលើសេចក្តីត្រូវការផ្នែកសុខភាពរបស់ប្អូនៗ។ ប្រព័ន្ធមើលថែសុខភាពរដ្ឋវិចតូរីយ៉ាមានរួមទាំង**កិច្ចបំរើជាច្រើន**។ ការមានសិទ្ធិទទួលយកការមើលថែដែលប្អូនៗត្រូវការ អាចមានន័យថាការបញ្ជូនប្អូនៗទៅកិច្ចបំរើ ផ្សេងពីកិច្ចបំរើដែលប្អូនៗបានជួបនៅលើកដំបូង។

ប្អូនៗអាចជ្រើសរើសធ្វើជា**អ្នកជម្ងឺឯកជន ឬសាធារណៈ**។ នៅក្នុងមន្ទីរពេទ្យសាធារណៈរដ្ឋវិចតូរីយ៉ា ប្រសិនបើប្អូនៗជាអ្នកជម្ងឺសាធារណៈ ប្អូនៗនឹងមិនត្រូវគេឲ្យបង់ថ្លៃមន្ទីរពេទ្យ ឬកិច្ចបំរើព្យាបាលរោគទេ។ ប្រសិនបើប្អូនៗជាអ្នកជម្ងឺឯកជន ប្អូនៗ ឬក្រុមហ៊ុនធានារ៉ាប់រងរបស់ប្អូនៗនឹងត្រូវគេឲ្យបង់ថ្លៃសំរាប់កិច្ចបំរើខ្លះៗ។ កិច្ចបំរើផ្នែកសុខភាពរបស់ប្អូនៗគួរពន្យល់ប្រាប់អំពីតម្លៃ ឬតម្លៃខុសគ្នាណាមួយចូលរួមនៅក្នុងការមើលថែរបស់ប្អូនៗ ប្រសិនបើប្អូនៗជាអ្នកជម្ងឺឯកជន។

ប្អូនៗអាចត្រូវគេឲ្យបង់ថ្លៃបន្តិចបន្តួច សំរាប់កិច្ចបំរើមើលថែសុខភាពសាធារណៈដែលរដ្ឋផ្គត់ផ្គង់ថវិកា ដូចជាការព្យាបាលធ្មេញ ឬការព្យាបាលរោគដោយធ្វើចលនាជាដើម។

## សុវត្ថិភាព

**ប្អូនៗមានសិទ្ធិទទួលយកការមើលថែសុខភាពដែលមានសុវត្ថិភាព និងគុណភាពខ្ពស់។ អ្នកជម្ងឺ អ្នកប្រើប្រាស់ និងស្ថាប័នផ្តល់ការមើលថែសុខភាព ទាំងអស់គ្នាមានសិទ្ធិទទួលយកបរិដ្ឋានមើលថែសុខភាពដែលមានសុវត្ថិភាព សន្តិសុខ និងជួយទំនុកបម្រុង។**

ប្អូនៗមានសិទ្ធិទទួលយក**ការមើលថែ និងការព្យាបាលដែលមានសុវត្ថិភាព**ប្រកបដោយបទដ្ឋានខ្ពស់។ សូម**ប្រាប់ឲ្យបុគ្គលិកបានដឹង** ប្រសិនបើប្អូនៗមានក្តីកង្វល់អំពីសុវត្ថិភាព ឬយល់ថាប្រហែលជាមានការប្រព្រឹត្តខុសឆ្គង។

សិទ្ធិរបស់ប្អូនៗដើម្បីទទួលយកការមើលថែដែលមានសុវត្ថិភាព និងគុណភាពខ្ពស់អាស្រ័យមួយផ្នែកទៅលើការទាក់ទងគ្នា**បានច្បាស់លាស់**។ នេះបានន័យថា ប្អូនៗត្រូវផ្តល់ឲ្យទៅស្ថាប័នផ្តល់ការមើលថែសុខភាពរបស់ប្អូនៗនូវព័ត៌មាន ដែលគេត្រូវការសំរាប់ព្យាបាលប្អូនៗ ហើយស្ថាប័នផ្តល់ការមើលថែសុខភាពរបស់ប្អូនៗ ត្រូវប្រាប់ប្អូនៗអំពីអ្វីដែលប្អូនៗត្រូវការដឹង ដើម្បីធ្វើការសំរេចអំពីការមើលថែរបស់ប្អូនៗ។

ប្អូនៗមានសិទ្ធិទទួលយក**អ្នកបកប្រែភាសាដែលរដ្ឋទទួលស្គាល់** ប្រសិនបើប្អូនៗត្រូវការម្នាក់ នៅពេលប្រើប្រាស់កិច្ចបំរើ**មើលថែសុខភាពសាធារណៈដែលរដ្ឋផ្គត់ផ្គង់ថវិកា** ដូចជាមន្ទីរពេទ្យ ឬមជ្ឈមណ្ឌលសុខភាពសហគមន៍ជាដើម។

គ្រប់កិច្ចបំរើមើលថែសុខភាពទាំងអស់ គួរបំពេញមុខការដើម្បីធ្វើឲ្យគុណភាពនៃការមើលថែរបស់គេបានកាន់តែប្រសើរជាបន្តទៅទៀត។ កិច្ចបំរើផ្នែកសុខភាពសាធារណៈរាយការណ៍អំពីរឿងនេះទៅឲ្យសហគមន៍ តាមរយៈរបាយការណ៍ប្រចាំឆ្នាំរបស់គេអំពីគុណភាពនៃការមើលថែ។

## ការគោរព

**ប្អូនៗមានសិទ្ធិដើម្បីឲ្យគេបង្ហាញថាមានការគោរព ឲ្យអ្នកដទៃប្រព្រឹត្តចំពោះខ្លួនប្រកបដោយភាពថ្លៃថ្នូ និងសេចក្តីរាប់អាន ហើយដោយគ្មានការប្រកាន់រើសអើង។ កិច្ចបំរើមើលថែសុខភាពគួរបង្កើតឲ្យមានបរិដ្ឋានដែលជួយទ្រទ្រង់សហប្រតិបត្តិការ និងការទាក់ទងរវាងអ្នកជម្ងឺ អ្នកប្រើប្រាស់ និងបុគ្គលិក។**

ប្អូនៗមានសិទ្ធិឲ្យគេប្រព្រឹត្ត**ដោយមានការគោរពចំពោះភាពថ្លៃថ្នូររបស់ប្អូនៗ**។ បុគ្គលិកមើលថែសុខភាពក៏សក្តិសមនឹងត្រូវបានគេប្រព្រឹត្តដោយមានការគោរព និងការយកចិត្តទុកដាក់ដោយគ្មានការប្រកាន់រើសអើងផងដែរ។

ប្អូនៗមានសិទ្ធិទទួលយកការមើលថែដែល**ឆ្លើយតបទៅនឹងវប្បធម៌ និងជំនឿរបស់ប្អូនៗ** ដូចជាជំនឿ និងការអនុវត្តន៍មាននៅជុំវិញការកើតការឈឺ និងការស្លាប់ ភេទរបស់អ្នកដែលព្យាបាលប្អូនៗ ឬតម្រូវការផ្នែកតមអាហារ ក្នុងកាលកំពុងព្យាបាលនៅក្នុងមន្ទីរពេទ្យ។

ប្អូនៗមានសិទ្ធិឲ្យគេព្យាបាល**ដោយគ្មានការប្រកាន់រើសអើង** ដែលសំអាងទៅលើពូជសាសន៍ អាយុ ភេទ អត្តសញ្ញាណនៃភេទ ចំណូលចិត្តខាងផ្លូវភេទ ឋានៈរបស់អ្នកមើលថែភាពពិការ ឋានៈជាប្តីប្រពន្ធ ឬជំនឿសាសនា។

កិច្ចបំរើមើលថែសុខភាពគួរផ្តល់ការមើលថែ និងការព្យាបាលក្នុង**បរិដ្ឋានដែលអនុញ្ញាតឲ្យមានការសម្ងាត់ផ្ទាល់ខ្លួន**តាម ដែលអាចធ្វើទៅបាន។

## ការទាក់ទង

**ការមើលថែសុខភាពដែលមានគុណភាពខ្ពស់ អាស្រ័យទៅលើការទាក់ទងពីរផ្លូវដែលបើកចំហ ហើយមានប្រសិទ្ធិភាពរវាងប្អូនៗ និងស្ថាប័នផ្តល់ការមើលថែសុខភាពរបស់ប្អូនៗ។ ប្អូនៗមានសិទ្ធិទទួលយកពត៌មានអំពីកិច្ចបំរើ ការព្យាបាល ជំរើស និងតម្លៃនៃការព្យាបាលក្នុងវិធីណាមួយដែលប្អូនៗអាចយល់បាន។**

ប្អូនៗមានសិទ្ធិទទួលយក**ពត៌មានដែលច្បាស់លាស់ ហើយអាចយល់បាន**អំពីការមើលថែសុខភាពរបស់ប្អូនៗ ហើយនិងល័ក្ខខ័ណ្ឌទាំងឡាយមានរាប់បញ្ចូលទាំងជំរើសនៃការព្យាបាល លទ្ធផលដែលត្រូវបានរំពឹងទុក ប្រតិកម្មរាយរងដែលអាចកើតមាន និងតម្លៃនៃការមើលថែ។ ស្ថាប័នផ្តល់ការមើលថែសុខភាពរបស់ប្អូនៗ គួរផ្តល់ឱកាសសំរាប់ប្អូនៗដើម្បីសួរសំនួរទាំងឡាយ។

ប្រសិនបើប្អូនៗមានកង្វល់អំពីជំរើសនៃការព្យាបាល ដែលស្ថាប័នផ្តល់ការមើលថែសុខភាពរបស់ប្អូនៗបានផ្តល់ជូន ប្អូនៗមានសិទ្ធិដើម្បីទទួលយក**យោបល់ផ្នែកព្យាបាលរោគជាលើកទីពីរ**។

មានកត្តាជាច្រើនដែលប៉ះពាល់ដល់សុខភាពរបស់ប្អូនៗៈ ប្រវត្តិសុខភាពរបស់ប្អូនៗ ថ្នាំព្យាបាល និងការព្យាបាលបំពេញដែលប្អូនៗកំពុងប្រើ ស្ថានភាពសង្គម សុខុមាលភាពផ្នែកអារម្មណ៍។ **នេះគឺជាការសំខាន់ដែលត្រូវផ្តល់ពត៌មាន ទាក់ទិនទាំងអស់ទៅឲ្យស្ថាប័នផ្តល់ការមើលថែសុខភាពរបស់ប្អូនៗ** ដើម្បីឲ្យគេអាចផ្តល់ជូនប្អូនៗនូវការព្យាបាលដ៏សមរម្យបំផុត។

ប្អូនៗមានសិទ្ធិទទួលយកអ្នកបកប្រែដែលរដ្ឋទទួលស្គាល់ **សំរាប់សេចក្តីត្រូវការផ្នែកទាក់ទងជាមួយកិច្ចបំរើមើលថែសុខភាពដែលរដ្ឋផ្គត់ផ្គង់ថវិកា។** អ្នកបកប្រែគួរទទួលបាននូវចំណុចសំខាន់ៗក្នុងរអម្លុងពេលនៃការមើលថែប្អូនៗ ដូចជានៅពេលពិភាក្សាអំពីប្រវត្តិសុខភាព ការព្យាបាល លទ្ធផលនៃការធ្វើតេស្ត រោគវិនិច្ឆ័យនៅក្នុងអម្លុងពេលចូលព្យាបាល និងការវាយតម្លៃ ហើយនិងនៅពេលដែលប្អូនៗតម្រូវឲ្យផ្តល់នូវការសំរេចបន្ទាប់ពីជ្រាបពត៌មានសព្វគ្រប់។

ប្រសិនបើប្អូនៗជាអ្នកជម្ងឺ ឬអ្នកប្រើប្រាស់នៅក្នុងមន្ទីរពេទ្យ ឬនៅក្នុងកិច្ចបំរើមើលថែសុខភាពធំៗដទៃទៀត ប្អូនៗប្រហែលត្រូវព្យាបាលដោយគ្រូពេទ្យជាច្រើន។ ប្អូនៗមានសិទ្ធិទទួលយកពត៌មាន **ថាតើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះការមើលថែរបស់ប្អូនៗ** ហើយថាតើត្រូវទាក់ទងជាមួយគេយ៉ាងដូចម្តេច។

ប្អូនៗមានសិទ្ធិ**ទាក់ទិនសមាជិកគ្រួសារ អ្នកមើលថែ ឬមនុស្សសំរាប់ជួយទ្រទ្រង់**ដែលបានជ្រើសរើសឲ្យជួយប្អូនៗ ក្នុងការទាក់ទងជាមួយស្ថាប័នផ្តល់ការមើលថែសុខភាពរបស់ប្អូនៗ។ មនុស្សនេះអាចជាមិត្តភក្តិ ឬសមាជិកគ្រួសារ ឬនរណាម្នាក់មកពីអង្គការជួយទ្រទ្រង់អ្នកប្រើប្រាស់។ ឧទាហរណ៍ មន្ទីរពេទ្យសាធារណៈនៅរដ្ឋវិចតូរីយ៉ាភាគច្រើនមានភ្នាក់ងារទំនាក់ទំនងជនជាតិអាប៉ូរីជីនី។ ចំពោះពត៌មានទាក់ទងលំអិត សូមមើលផ្នែកខាងក្រោយនៃកូនសៀវភៅនេះ។

## ការចូលរួម

**ប្អូនៗមានសិទ្ធិទទួលនូវមុខនាទីយ៉ាងសកម្មក្នុងការមើលថែសុខភាពរបស់ប្អូនៗ ហើយឲ្យគេរាប់បញ្ចូលនៅក្នុងការសំរេច និងការជ្រើសរើសអំពីការមើលថែរបស់ប្អូនៗ។**

ប្អូនៗមានសិទ្ធិ**ចូលរួមយ៉ាងពេញទំហឹង តាមដែលប្អូនៗប្រាថ្នា ក្នុងការសំរេចអំពីការមើលថែ និងការព្យាបាលរបស់ប្អូនៗ។** ស្ថាប័នផ្តល់ការមើលថែសុខភាពរបស់ប្អូនៗ គួរផ្តល់ជូនប្អូនៗនូវពត៌មានទាំងអស់ដែលប្អូនៗត្រូវការ ដើម្បីធ្វើការសំរេចបន្ទាប់ពីជ្រាបពត៌មានសព្វគ្រប់ ឱកាសដើម្បីសួរសំនួរទាំងឡាយ និងពេលវេលាដើម្បីនិយាយជាមួយអ្នកមើលថែ គ្រួសារ និងមិត្តភក្តិរបស់ប្អូនៗ មុនពេលធ្វើការសំរេច។

ប្អូនៗមានសិទ្ធិ**ឲ្យគ្រួសាររបស់ប្អូនៗ អ្នកមើលថែដទៃទៀត ឬមនុស្សសំរាប់ជួយទ្រទ្រង់ដែលបានជ្រើសរើស**ឲ្យចូលរួមនៅក្នុងការមើលថែរបស់ប្អូនៗ។ ដោយមានការយល់ព្រមពីប្អូនៗ គេក៏អាចទទួលបាននូវពត៌មាន ហើយទាក់ទិននៅក្នុងការធ្វើសេចក្តីសំរេចអំពីការមើលថែរបស់ប្អូនៗ ជាមួយប្អូនៗផងដែរ។

ប្អូនៗមាន**សិទ្ធិបដិសេធទទួលយកការព្យាបាល**។ ក៏ប៉ុន្តែទោះជាយ៉ាងណាក្តីក្នុងកាលៈទេសៈខ្លះ ប្អូនៗអាចត្រូវគេចាត់ទុកថាពុំមានសមត្ថភាពនឹងផ្តល់ការយល់ព្រមបន្ទាប់ពីជ្រាបពត៌មានសព្វគ្រប់ ឬបដិសេធទទួលការព្យាបាលឡើយ។

ប្អូនៗមានសិទ្ធិ**តែងតាំងអ្នកណាម្នាក់ឲ្យធ្វើការសំរេចផ្នែកព្យាបាលរោគសំរាប់ប្អូនៗ** ក្នុងករណីយដែលប្អូនៗបាត់បង់សមត្ថភាពក្នុងការធ្វើដូច្នេះ។ ចំពោះពត៌មានបន្ថែម សូមទាក់ទងមកការិយាល័យគាំទ្រសាធារណៈ - ចំពោះពត៌មានទាក់ទងលំអិត សូមមើលផ្នែកខាងក្រោយនៃកូនសៀវភៅនេះ។

ប្រសិនបើប្អូនៗជាអ្នកជម្ងឺព្យាបាលនៅមន្ទីរពេទ្យ ប្អូនៗមានសិទ្ធិចូលរួមក្នុងការធ្វើសេចក្ដីសំរេចថា**តើប្អូនៗត្រូវចាកចេញពីមន្ទីរពេទ្យយ៉ាងដូចម្ដេច ហើយនៅពេលណា។** មុនពេលប្អូនៗចាកចេញមន្ទីរពេទ្យ គួរពិភាក្សាថាតើកិច្ចបំរើមើលថែសុខភាពណាខ្លះដែលប្អូនៗអាចត្រូវការ ក្រោយពេលប្អូនៗចាកចេញពីមន្ទីរពេទ្យ ហើយបញ្ជូនប្អូនៗទៅឯ កិច្ចបំរើទាំងនោះ។ ប្អូនៗមានសិទ្ធិចូលរួមនៅក្នុងសេចក្ដីសំរេចអំពីការមើលថែប្អូនៗដែលកំពុងមានបន្ត។ វេជ្ជបណ្ឌិតពិគ្រោះរោគទូទៅរបស់ប្អូនៗគួរចូលរួមផងដែរ។ ប្អូនៗអាចចាកចេញពីមន្ទីរពេទ្យដោយខ្លួនឯង ជំទាស់នឹងដំបូន្មានរបស់វេជ្ជបណ្ឌិតប្អូនៗ ក៏ប៉ុន្តែប្អូនៗប្រហែលជាត្រូវគេស្នើសុំឲ្យចុះហត្ថលេខាលើហ្វមទទួលខុសត្រូវចំពោះរឿងនេះ។

មានឱកាសជាច្រើនដើម្បី**ចូលរួមនៅក្នុងការធ្វើផែនការ ការរៀបចំ និងការវាយតម្លៃកិច្ចបំរើមើលថែសុខភាពសាធារណៈ**។ អង្គការជាច្រើនពិចារណាអំពីសារៈសំខាន់នៃបទពិសោធន៍ និងគំនិតរបស់អ្នកប្រើប្រាស់អំពីកិច្ចបំរើរបស់គេ នៅពេលធ្វើឲ្យកិច្ចបំរើបានល្អប្រសើរឡើង។ ប្អូនៗមានសិទ្ធិចែកចាយមតិរបស់ប្អូនៗ ឧទាហរណ៍ ដោយការបំពេញពាក្យស្ទង់មតិ ការចូលរួមនៅក្នុងគណៈកម្មការផ្ដល់ឱវាទសំរាប់សហគមន៍ ការសរសេរលិខិត ឬការនិយាយប្រាប់បុគ្គលិកអំពីបទពិសោធន៍ទាំងឡាយរបស់ប្អូនៗ។ ការផ្ដល់យោបល់ត្រឡប់មកវិញទាំងវិជ្ជមាន និងអវិជ្ជមានសុទ្ធតែមានប្រយោជន៍ទាំងអស់។

## កិច្ចការឯកជន

**ច្បាប់ប្រទេសអូស្ត្រាលី និងរដ្ឋវិចតូរីយ៉ាការពារកិច្ចការឯកជន និងការសម្ងាត់នៃរឿងសុខភាពផ្ទាល់ខ្លួនរបស់ប្អូនៗ និងពត៌មានដទៃទៀត។ ពត៌មានត្រូវបានគេប្រមូលយកប្រើប្រាស់ រក្សាទុក និងចែកចាយដោយអនុលោមទៅតាមច្បាប់ទាំងនេះ។**

មនុស្សគ្រប់រូបដែលចូលរួមនៅក្នុងការព្យាបាល និងការមើលថែរបស់ប្អូនៗ មាន**ករណីកិច្ចផ្នែកវិជ្ជាជីវៈ និងផ្លូវច្បាប់ ដើម្បីរក្សាពត៌មានអំពីប្អូនៗជាសម្ងាត់**។ ជួនកាលស្ថាប័នផ្តល់ការមើលថែសុខភាពរបស់ប្អូនៗ ត្រូវការចែករំលែកពត៌មានអំពីប្អូនៗ ជាមួយអ្នកដទៃទៀតដែលចូលរួមនៅក្នុងការមើលថែរបស់ប្អូនៗ។ គេនឹងចែករំលែកពត៌មានរបស់ប្អូនៗ ជាមួយអ្នកណាម្នាក់ដែលពុំទាក់ទិនក្នុងការមើលថែលោក ដោយមានការ**ការអនុញ្ញាតពីប្អូនៗតែប៉ុណ្ណោះ**។ **ច្បាប់កំណត់ត្រាផ្នែកសុខភាព ឆ្នាំ២០០១ រដ្ឋវិចតូរីយ៉ា** បញ្ជាក់ប្រាប់អំពីគោលការណ៍ភាពឯកជន ដែលគ្រប់ទាំងកិច្ចបំរើសុខភាពទាំងអស់ត្រូវអនុវត្តតាម។

ប្អូនៗមានសិទ្ធិ**បញ្ចេញមតិអំពីអ្វីដែលបានកើតឡើងចំពោះពត៌មានរបស់ប្អូនៗ**។ ប្រសិនបើប្អូនៗសំរេចពុំឲ្យមានការចែកចាយពត៌មានខ្លះរបស់ប្អូនៗទេ ឬកម្រិតលទ្ធភាពការប្រើប្រាស់ពត័មាននៅក្នុងកំណត់ត្រាសុខភាពរបស់ប្អូន នេះគឺជាសិទ្ធិរបស់ប្អូនៗ ក៏ប៉ុន្តែការនេះអាចប៉ះពាល់ដល់សមត្ថភាពរបស់ស្ថាប័នផ្តល់ការមើលថែរបស់ប្អូនៗ ក្នុងការផ្តល់ជូនប្អូនៗនូវការមើលថែល្អបំផុតដែលអាចធ្វើទៅបាន។

ប្អូនៗមានសិទ្ធិទទួលយកកំណត់ត្រាផ្នែកសុខភាពរបស់ប្អូនៗ។ សូមប្រាប់ស្ថាប័នផ្តល់ការមើលថែរបស់ប្អូនៗ ប្រសិនបើមានពត៌មានណាមួយពុំត្រឹមត្រូវ ពុំពេញលេញ ឬពុំបានរក្សាទុកទាន់ពេល។ នៅក្នុងករណីខ្លះ ប្អូនៗប្រហែលជាត្រូវគេផ្តល់ឲ្យតែមួយផ្នែកនៃកំណត់ត្រារបស់ប្អូនៗប៉ុណ្ណោះ។ ប្រសិនបើដូច្នេះមែន ប្អូនៗមានសិទ្ធិដាក់ពាក្យសុំនៅក្រោមច្បាប់សេរីភាពដើម្បីទទួលយកពត៌មាន ដើម្បីទទួលយកកំណត់ត្រាពេញលេញរបស់ប្អូនៗ។ ចំពោះពត៌មានបន្ថែម សូមសួរអ្នកតំណាងអ្នកជម្ងឺរបស់ប្អូនៗ ឬសមាជិកបុគ្គលិកដែលទាក់ទិន - ចំពោះពត៌មានទាក់ទងលំអិត សូមមើលផ្នែកខាងក្រោយនៃកូនសៀវភៅនេះ។

## យោបល់

**ប្អូនៗមានសិទ្ធិបញ្ចេញយោបល់អំពីការមើលថែសុខភាពរបស់ប្អូនៗ និងដើម្បីលើកយកការព្រួយបារម្ភរបស់ប្អូនៗមកឲ្យគេដោះស្រាយ។ កិច្ចបំរើមើលថែសុខភាពគួររៀបចំពត៌មានអំពីដំណើរការផ្តល់យោបល់ត្រឡប់មកវិញ ឲ្យអាចងាយស្រួលនឹងរកឃើញ។**

ប្អូនៗមានសិទ្ធិបញ្ចេញយោបល់ **សួរសំនួរ និងធ្វើការតវ៉ា**អំពីការមើលថែសុខភាពរបស់ប្អូនៗ។

នេះគឺជាការល្អបំផុតដែលគួរសាក**ល្បងដោះស្រាយក្តីកង្វល់ទាំងឡាយ ជាមួយស្ថាប័នផ្តល់ការមើលថែសុខភាពរបស់ប្អូនៗ**ជាមុនសិន។ កិច្ចបំរើមើលថែសុខភាពចង់ដោះស្រាយបញ្ហាឲ្យបានឆាប់ជាទីបំផុត ក៏ប៉ុន្តែគេត្រូវការដឹងអំពីបញ្ហានោះជាមុនសិន។ សូមសាកល្បងផ្តល់យោបល់ត្រឡប់មកវិញតាមរបៀបដែលគោរពដល់អ្នកប្រើប្រាស់ដទៃទៀត និងស្ថាប័នផ្តល់ការមើលថែសុខភាព។

កិច្ចបំរើមើលថែសុខភាពធ្វើកំណត់ត្រាផ្តល់**យោបល់ត្រឡប់មកវិញទាំងវិជ្ជមាន និងអវិជ្ជមាន** ឧទាហរណ៍ តាមការស្ទង់មតិ ដំណើរការផ្តល់យោបល់ត្រឡប់មកវិញ និងការតវ៉ា។ ការផ្តល់យោបល់ត្រឡប់មកវិញរបស់ប្អូនៗ គួរត្រូវបានគេយកប្រើប្រាស់ដើម្បីធ្វើឲ្យកិច្ចបំរើបានល្អប្រសើរឡើងក្នុងពេលអនាគត។

នៅក្នុងមន្ទីរពេទ្យ ប្រសិនបើប្អូនៗពុំពេញចិត្តនឹងរបៀបដែលវេជ្ជបណ្ឌិត ឬក្រុមអ្នកព្យាបាលរបស់ប្អូនៗឆ្លើយតបទៅនឹងក្តីកង្វល់របស់ប្អូនៗទេ ប្អូនៗមានសិទ្ធិ**និយាយទៅកាន់អ្នកតំណាងអ្នកជម្ងឺប្រចាំមន្ទីរពេទ្យ**។

ប្រសិនបើប្អូនៗពុំពេញចិត្តនឹងរបៀបដែលកិច្ចបំរើមើលថែសុខភាពរបស់ប្អូនៗ ឬអ្នកតំណាងអ្នកជម្ងឺឆ្លើយតបទៅនឹងក្តីកង្វល់របស់ប្អូនៗទេ ប្អូនៗមានសិទ្ធិធ្វើការ**តវ៉ាទៅស្នងការកិច្ចបំរើសុខភាពរដ្ឋវិចតូរីយ៉ា**។ ចំពោះពត៌មានទាក់ទងលំអិត សូមមើលផ្នែកខាងក្រោយនៃកូនសៀវភៅនេះ។

# ពត៌មានបន្ថែម

## ការប្រើប្រាស់ធម្មនុញ្ញ

ពត៌មានបន្ថែមទូទាំងប្រទេសអំពីធម្មនុញ្ញអូស្ត្រាលីស្តីអំពីសិទ្ធិមើលថែសុខភាព អាចទទួលយកបាននៅតាមវិបសាយ www.safetyandquality.gov.au។ សូមមើលនៅត្រង់វិបសាយ www.patientcharter.health.vic.gov.au ដើម្បីឲ្យបានដឹងបន្ថែមអំពីបែបយ៉ាងណាដែលធម្មនុញ្ញអនុវត្តនៅក្នុងរដ្ឋវិចតូរីយ៉ា មានរួមទាំងធនធានដើម្បីជួយកិច្ចបំរើមើលថែសុខភាពប្រើប្រាស់ធម្មនុញ្ញ នៅក្នុងមុខការរបស់គេ។

## ការជួយទ្រទ្រង់មាននៅក្នុងកិច្ចបំរើមើលថែសុខភាពរបស់ប្អូនៗ

នៅតាមមន្ទីរពេទ្យសាធារណៈធំៗមានអ្នកតំណាងអ្នកជម្ងឺ ហើយភាគច្រើនមានភ្នាក់ងារទំនាក់ទំនងជនជាតិអាបូរីជីនី។ កិច្ចបំរើសុខភាពផ្លូវចិត្តជាច្រើនមានអ្នកគាំទ្រអ្នកប្រើប្រាស់ និងអ្នកមើលថែ។ កិច្ចបំរើមើលថែសុខភាពរបស់ប្អូនៗ អាចមានដាក់ជាបញ្ជីរាយឈ្មោះពត៌មានទាក់ទងរបស់បុគ្គលិកនៅខាងក្រោមនេះ។

គ្រប់កិច្ចបំរើសុខភាពសាធារណៈទាំងអស់ អាចទទួលយកអ្នកបកប្រែភាសាដែលរដ្ឋទទួលស្គាល់។ អ្នកបកប្រែភាសាអាចមានផ្តល់នៅតាមទីកន្លែង ឬអាចទទួលយកបានតាមទូរស័ព្ទមកពីទីភ្នាក់ងារខាងក្រៅ។

## ពត៌មានទាក់ទងដ៏មានប្រយោជន៍

អង្គការទាំងនេះអាចជួយដោះស្រាយការតវ៉ា ឬជួយប្អូនៗដែលជាអ្នកប្រើប្រាស់។ សូមបើកមើលនៅត្រង់វិបសាយ www.patientcharter.health.vic.gov.au ដើម្បីទទួលយកពត៌មានទាក់ទងដ៏មានប្រយោជន៍ថែមទៀត។

### ស្នងការកិច្ចបំរើផ្នែកពិការភាព (Health Services Commissioner)

**ទូរស័ព្ទ:** (03) 8601 5200
**ទូរស័ព្ទឥតគិតថ្លៃ:** 1800 136 066
TTY: 1300 550 275
**អាស័យដ្ឋាន:** 30th floor, 570 Bourke Street, Melbourne Victoria 3000
**វិបសាយ:** www.health.vic.gov.au/hsc

### ស្នងការកិច្ចបំរើផ្នែកពិការភាព (Disability Services Commissioner)

**ទូរស័ព្ទ:** 1300 728 187
**ទូរស័ព្ទឥតគិតថ្លៃ:** 1800 677 342
TTY: 1300 726 563
**អ៊ីម៉េល:** complaints@odsc.vic.gov.au
**អាស័យដ្ឋាន:** 30th floor, 570 Bourke Street, Melbourne Victoria 3000
**វិបសាយ:** www.odsc.vic.gov.au

### ស្នងការឱកាសស្មើគ្នា និងសិទ្ធិមនុស្ស រដ្ឋវិចតូរីយ៉ា (Victorian Equal Opportunity and Human Rights Commission)

**ទូរស័ព្ទ:** (03) 9281 7100
TTY: (03) 9281 7110
**អ៊ីម៉េល:** complaints@veohrc.vic.gov.au
**អាស័យដ្ឋាន:** Level 3, 380 Lonsdale Street, Melbourne VIC 3000
**វិបសាយ:** www.equalopportunitycommission.vic.gov.au

### ការិយាល័យជួយទ្រទ្រង់សាធារណៈ: (The Office of the Public Advocate)

**ទូរស័ព្ទ:** (ទូរស័ព្ទឥតគិតថ្លៃ): 1300 309 337
TTY: (03) 9603 9529
ACE: 133677 (03) 9603 9500
**អាស័យដ្ឋាន:** Level 5, 436 Lonsdale Street, Melbourne Victoria 3000
**វិបសាយ:** www.publicadvocate.vic.gov.au

**ប្រសិនបើប្អូនៗមានក្តីកង្វល់ ឬសំនួរអំពីការមើលថែរបស់ប្អូនៗនៅក្នុងកិច្ចបំរើនេះ សូមទាក់ទង:**

---

(សូមដាក់ពត៌មានទាក់ទងលំអិតរបស់ភ្នាក់ងារទំនាក់ទំនងជនជាតិអាប៊ូរីជីនី និងអ្នកតំណាងអ្នកជម្ងឺនៅត្រង់កន្លែងនេះ)

A Victorian
Government
initiative